Declassified to Public
08 April 2021

លេខ / N°: D268

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

ចំពោះមុខ ៖ សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទ ៖ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ភាសាដើម ៖ ខ្មែរ

ចំណាត់ថ្នាក់ឯកសារ ៖ សម្ងាត់

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 11 / 2018
ម៉ោង (Time/Heure): 12:00
មន្ត្រីមទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

# ដីកាសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

ផ្ញើជូន:-

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**
**អាង ឧត្តម**
Michael KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវន
ទី ស្រីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Martine JACQUIN
Daniel MCLAUGHLIN
Yiqiang LIU
Lyma NGUYEN
Nushin SARKARATI

01596672



## I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត("ស.ច.ស") នៅក្នុងសំណុំរឿង០០៣ បានចុះបញ្ជីនៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried BLUNK បានបិទការស៊ើបសួរសំណុំរឿង ០០៣។

៣. ចាប់ពីពេលការបើកការស៊ើបសួរសំណុំរឿង ០០៣ រហូតដល់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១ ដែលជាកាលបរិច្ឆេទចុងក្រោយនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានមនុស្សចំនួន ០៤ នាក់បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៣។

៤. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ និងថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១ ដោយផ្អែកលើឯកសារដែលបានដាក់មុនការបិទការស៊ើបសួរ ស.ច.ស បានប្រកាសថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់មនុស្សទាំង ០៤ ខាងលើ ឈ្មោះ សេង ចាន់ធារី, Robert Hamill, ជុំ នៅ និង Timothy Scott Deeds មិនអាចទទួលយកបានឡើយ[1]។ អ្នកដាក់ពាក្យសុំទាំងនេះបានប្តឹងជំទាស់សេចក្តីសម្រេចនេះ[2]។

---

[1] សំណុំរឿង០០៣-D11/1/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ សំណុំរឿង០០៣-D11/2/3 *ដីកាសម្រេចស្តីពីការទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Rob Hamill* ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។ សំណុំរឿង០០៣-D11/3/3 *ដីកាសម្រេចស្តីអំពីភាពអាចទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ* ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១១។

[2] សំណុំរឿង០០៣-D11/1/4/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សេង ចាន់ធារី* ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១។ សំណុំរឿង ០០៣-D11/2/4/2 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill* ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១១។ សំណុំរឿង ០០៣-D11/4/4/1 *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ Timothy Scott DEEDS* ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១១។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១

01596673



៥. នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១, ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០១២ និងថ្ងៃទី ១៣ និង ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០១៣ អង្គបុរេជំនុំជម្រះមិនអាចរកសម្លេងភាគច្រើនគ្រប់គ្រាន់ ដើម្បីសម្រេចសេចក្តីលើបណ្តឹងជំទាស់របស់អ្នកដាក់ពាក្យសុំទាំង ០៤ នាក់បានឡើយ[3]។

៦. នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ សេង ចាន់ធារី បានដកពាក្យសុំរបស់គាត់ចេញពីសំណុំរឿង ០០៣[4]។ ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ការដកពាក្យសុំនេះ តាមរយៈលិខិតចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤[5]។

៧. ក្រោយថ្ងៃ ១៤ ខែ ឧសភា ឆ្នាំ ២០១១ រហូតមកដល់ថ្ងៃចេញដីកាសម្រេចនេះ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៤២ ផ្សេងទៀត ត្រូវបានដាក់ជូនសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## II. ពិភាក្សា

៨. វិធានផ្ទៃក្នុង ២៣ស្ទួន ចែងថា"*ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ ១៥ ថ្ងៃ បន្ទាប់ពីសហចៅក្រម*

---

[3] សំណុំរឿង០០៣-D11/2/4/4 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីលោក Robert Hamill* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ សំណុំរឿង០០៣-D11/1/4/2 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សេង ចាន់ធារី* ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១២។ សំណុំរឿង០០៣-D11/3/4/2 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជុំ នៅ* ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣។ សំណុំរឿង០០៣-D11/4/4/2 *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី Timothy Scott DEEDS* ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[4] សំណុំរឿង០០៣-D11/1/5 *សំណើសុំដកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី 11-VSS-00001 របស់ សេង ចាន់ធារី* ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤។

[5] សំណុំរឿង០០៣-D11/1/6 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី ជួង ជូងី* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៣-D11/1/7 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី សំ សុគង់* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។ សំណុំរឿង០០៣-D11/1/8 *លិខិតរបស់ក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្ញើជូនមេធាវី Emmanuel Jacomy* ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤។

*ស៊ើបអង្កេតជូនដំណឹងដល់ ភាគីទាំងអស់អំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ ដោយអនុលោមតាមវិធាន ៦៦(១)* "។

៩. ផ្អែកតាមវិធានផ្ទៃក្នុង ២៣ ស្ទួន ខាងលើ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតទាំងពីរបានបិទការស៊ើបសួរសំណុំរឿង ០០៣ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដូច្នេះ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១ ជាកាលបរិច្ឆេទចុងក្រោយនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried BLUNK។ ហេតុដូចនេះ ពាក្យសុំដែលដាក់ក្រោយថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១ នឹងមិនត្រូវលើកយកមកពិចារណានោះទេ ដោយសារកំហុសផ្នែកនីតិវិធី ដូចដែលយើងបានលើកឡើងនៅក្នុងដីកាសម្រេចលើកលើងការចោទប្រកាន់ប្រឆាំង មាស មុត ត្រង់កថាខណ្ឌ ១៨[6]។

១០. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៤ ដែលបានដាក់មុនក្នុងអំឡុងពេលស៊ើបសួរ រហូតដល់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១ ត្រូវបានសម្រេច បដិសេធជាស្ថាពររួចហើយ។ ដូច្នេះ ពាក្យសុំចំនួន ៦៤២ ដែលត្រូវបានដាក់ក្រោយ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១ នឹងមិនត្រូវលើកយកមកពិចារណាឡើយ។

**តាមសំអាងហេតុខាងលើយើង ៖**

១១. **លើកចោល** ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលបានដាក់ក្រោយ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១។

ថ្ងៃ ពុធ ៦ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**សហចៅក្រមស៊ើបអង្កេតជាតិ**

National Co-Investigating Judge

Co-juge d'instruction national

**យូ ប៊ុនឡេង**

[6] សំណុំរឿង០០៣-D266 *ដីកាសម្រេចលើកលែងការចោទប្រកាន់ប្រឆាំង មាស មុត* ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨។